ភាសាខ្មែរ

① អត្ថបទនេះដកស្រង់ចេញពីរឿង «តេជោយ៉ត (ភាគទី17) អ្នកនិពន្ធឈ្មោះ ទៅ ជិច្ចត តែងក្នុងឆ្នាំ 1983 ។

② បញ្ហាដែលជាឧបសគ្គរារាំងជំទាវស្រួន ក្នុងការសម្រេចចិត្តស្នេហារវាង តេជោយ៉ត និងនាង មាន ៖
- តេជោយ៉តគ្រាន់ជាខ្ញុំកញ្ជះនាង
- តេជោយ៉តជាជនជាតិភាគតិច
- សង្គមមានការបែងចែកវណ្ណៈ មានការរើសអើងរវាងវណ្ណៈមួយទៅវណ្ណៈមួយ និងរវាងជនជាតិមួយទៅជនជាតិមួយទៀត ។

③ ដើម្បីឱ្យជំទាវស្រួនភ្ញាក់រលឹក តេជោយ៉តបានប្រើបញ្ញាញាណ ឆ្លៀតយកការជំនឿព្រះរបស់ជំទាវស្រួនមកភ្ជាប់ ធ្វើរូបសំណាកតេជោមាស និងព្រះពុទ្ធរូប ដោយការលាបពណ៌ស្រស់ស្អាត និងតុបតែងយ៉ាងវិចិត្រ ហើយបានប្រារព្ធធ្វើពិធីបុណ្យឆ្លងយ៉ាងអធិកអធម ។ លោកក៏បានអញ្ជើញជំទាវស្រួនមកទស្សនា នៅពេលនាងឃើញរូបសំណាកប្ដីនាង និងព្រះពុទ្ធរូប នាងក៏បាត់ដឹងស្មារតី ។ ពេលដែលតេជោយ៉តឃើញនាងដឹងសតិ តេជោយ៉តក៏បានប្រាប់ថារូបសំណាកទាំងពីរនេះ គឺជាការជំនឿព្រះជំទាវ ដែលគោរពរាល់ថ្ងៃ ។ ជំទាវស្រួនយល់ពីបញ្ហានេះ នាងក៏ភ្ញាក់រលឹក ព្រមទទួលយកតេជោយ៉តធ្វើជាស្វាមី និងលុបប្រកាន់វណ្ណៈ និងប្រកាន់ពូជសាសន៍ ។

④ តម្លៃអប់រំក្នុងអត្ថបទ ៖
- អប់រំមនុស្សកុំឱ្យរើសអើងវណ្ណៈ ពូជសាសន៍ ។
- អប់រំកុំឱ្យប្រកាន់វណ្ណៈក្នុងសង្គម
- អប់រំឱ្យមានស្មារតីស្នេហាជាតិ
- អប់រំឱ្យមានភក្ដីភាពចំពោះមាតុភូមិ

⑤ សំណេរ

នៅក្នុងសង្គមរស់នៅរបស់មនុស្សគ្រប់សម័យកាលទាំងអស់ មិនថាជនជាតិណាជាជនជាតិណា មានខ្មែរ ជនជាតិភាគតិច ចិន យួន អឺរ៉ុប ជាដើម គឺត្រូវតែមានអ្នកមាន អ្នកក្រ អាក្រក់ ល្អ ស ខ្មៅ អ្នកតូច អ្នកធំ អ្នកទាំងអស់នោះ មានមួយចំនួនចេះស្រលាញ់រាប់អានគ្នា និងមួយចំនួនទៀតមានការរើសអើងវណ្ណៈ ពូជសាសន៍ ។ ដូចនេះទើបមានទស្សនៈមួយលើកឡើងថា «ការប្រកាន់វណ្ណៈ និងការប្រកាន់ពូជសាសន៍ នៅតែដិតជាប់ក្នុងផ្នត់គំនិតរបស់ប្រជាជនខ្មែរយើង ។

តើយើងជាយុវជនជំនាន់ក្រោយត្រូវធ្វើដូចម្ដេចខ្លះ ដើម្បីលុបបំបាត់ផ្នត់គំនិតនេះឱ្យអស់ពីសង្គមខ្មែរយើង ?

ដើម្បីងាយស្រួលក្នុងការបកស្រាយប្រធានបទនេះឱ្យកាន់តែច្បាស់ និងស៊ីជម្រៅ យើងគួរតែស្វែងយល់ន័យពាក្យគន្លឹះមួយចំនួនជាមុនសិន ។ ការប្រកាន់វណ្ណៈ មានន័យថា គឺការប្រកាន់នូវពណ៌សម្បុរ និងពូជពង្សវង្សត្រកូល និងប្រកាន់នូវជាតិសាសន៍ គឺនៅតែដិតជាប់ក្នុងគំនិតរបស់ប្រជាជនខ្មែរយើង ។

ជាការពិតណាស់ ការប្រកាន់វណ្ណៈ និងពូជសាសន៍ ជាបញ្ហាមួយដែលមនុស្សយើងមិនមានគំនិតនឹកនាចជាប់ជានិច្ច ក្នុងសង្គម ស្រទាប់វណ្ណៈ គឺតែងតែកើតមាន មិនថាអ្នកណា ឬអ្នកណានោះទេ ។ ជាក់ស្ដែងនៅក្នុងសង្គមខ្មែររបស់យើង ប្រជាជនក្នុងរបបប៉ុលពត យើងឃើញថាប្រជាជនមានការប្រកាន់បក្សពួក គឺពួកអ្នកចាស់ និងអ្នកថ្មី ។ ពេលនោះ អ្នកចាស់បានកៀបសង្កត់អ្នកថ្មី មើលងាយ ជេរដៀល និយាយចំអកឡកឡឺយ ដាក់ពួកអ្នកថ្មីគ្មានស្រាកស្រាន្ត ។ ចំណែកនៅក្នុងរឿងតេជោយ៉តវិញ យើងឃើញថា ជំទាវស្រួនជាស្ត្រីស្រស់ស្អាត និងប្រាជ្ញាឈ្លាសវៃ ។ ប៉ុន្តែនាងនៅតែមានការ

[illegible]ដ៏ពោរពេញដោយ[illegible] ដែលស្រលាញ់ [illegible] ជាអ្នកបង្កើត និង[illegible] ជាតិភាគតិច ហើយ[illegible] [illegible] ។

ក្នុងនាមយើងជាយុវជនជំនាន់ក្រោយ ដើម្បីឲ្យប្រទេសយើងមានភាពសុខសប្បាយ និងការរីកចំរើន [illegible] យើងមិនត្រូវប្រកាន់វណ្ណៈ ពូជសាសន៍ ពណ៌សម្បុរនោះទេ ។ យើងត្រូវតែស្រលាញ់រាប់អានគ្នា សហការគ្នា មិនថាអ្នកនោះក្រ [illegible] ទាបខ្ពស់ [illegible] ជាតិសាសន៍ [illegible] នោះទេ ។ [illegible] ត្រូវតែបង្កើត[illegible] និង[illegible]ទៅវិញទៅមក [illegible] និងអភិវឌ្ឍន៍សង្គម ។ ព្រោះយើងមិនអាចរស់នៅ[illegible] មនុស្សគ្រប់ជាតិសាសន៍ [illegible] នោះទេ ។ [illegible] យើងជាយុវជនជំនាន់ក្រោយ [illegible]បំផុត ដែលមិនអាចខ្វះបាន នោះគឺសាមគ្គីភាព។ [illegible] និងការទំនាក់ទំនងគ្រប់វណ្ណៈ ជាតិសាសន៍ ដែលអាចធ្វើឲ្យយើង[illegible] បានភាពជោគជ័យ និងធ្វើឲ្យជាតិសាសន៍ផ្សេងៗកាន់តែស្គាល់ និងស្រលាញ់ចូលចិត្ត [illegible]របស់យុវជនខ្មែរយើង ហើយ[illegible] មានការរើសអើងទៀតផង ។ ជាការពិតនៅក្នុងប្រទេសយើង [illegible] បានបើកចំហរយ៉ាងទូលាយចំពោះ [illegible] គ្រប់ជាតិសាសន៍ ឲ្យមកទស្សនាកំសាន្ត នៅក្នុងប្រទេសយើង ដូចជាប្រាសាទ[illegible] ព្រះវិហារ និងរមណីយដ្ឋានផ្សេងៗនៅក្នុងប្រទេសយើង ។ យើងទទួលពួកគាត់យ៉ាង[illegible] រាក់ទាក់ ធ្វើឲ្យពួកគេចូលចិត្តប្រទេសយើង និងមានការសប្បាយចិត្ត ។ យើងសិក្សាពីវប្បធម៌របស់ពួកគេ ហើយពួកគេសិក្សាពីវប្បធម៌របស់ពួកយើង[illegible] មានភាពស្និទ្ធស្នាល [illegible] ជាក់ស្ដែងនៅក្នុង[illegible] [illegible] ជាជនជាតិភាគតិច [illegible] ប៉ុន្តែ[illegible] [illegible] ជាតិ [illegible] [illegible] ជាមនុស្សដែល [illegible] ក្នុងកិច្ចការផ្សេងៗ [illegible] ក្នុងការ[illegible] សត្រូវ និងជាមនុស្សដែល[illegible] ។ [illegible] ឲ្យ[illegible] ដែលមានឋានៈ [illegible] ដែលប្រកាន់វណ្ណៈ ពូជសាសន៍ ហើយត្រូវទទួលយកគេ[illegible] ។

សរុបសេចក្ដីមកការដែលមនុស្សយើងទាំងអស់ស្រលាញ់រាប់អានគ្នា [illegible]គ្នា ដោយមិនប្រកាន់វណ្ណៈ ពូជសាសន៍ ពណ៌សម្បុរនោះ គឺពិតជាបាននាំឲ្យមនុស្សក្នុងសង្គមមិនមានភាពវឹកវរ និងនាំឲ្យសង្គមជាតិ និងប្រទេសយើងពិតជាបាន[illegible] កាន់តែល្អប្រសើរ ។

[illegible]តាមការបកស្រាយមតិប្រធានខាងលើនេះ នាំឲ្យយើងសន្និដ្ឋានបានថា មតិរបស់ប្រធានមានន័យយ៉ាងត្រឹមត្រូវបំផុត ដែលបានបញ្ជាក់[illegible] ឲ្យយុវជនយើង[illegible] នូវគំនិតប្រកាន់វណ្ណៈ រើសអើងពូជសាសន៍ ហើយខិតខំរកវិធីល្អៗ [illegible] គំនិតនេះ [illegible] សង្គមយើង ។ ជាចុងក្រោយនេះ ក្នុងនាមយើងជាយុវជនជំនាន់ក្រោយត្រូវតែរួបរួម ស្រលាញ់សាមគ្គីជាធ្លុងមួយ ដើម្បីកសាងប្រទេសយើង និង[illegible]ចំណងមិត្តភាពចំពោះជាតិយើង និងជាតិដទៃ ឲ្យកាន់តែជិតស្និទ្ធ ។/